01581838

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារលេខ D370/1/1/6

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥១)

**អង្គបុរេជំនុំជម្រះ**

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Oliver BEAUVALLET
ចៅក្រម ន៉ីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 08 / 2018
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ: កោសលុប**

**សេចក្តីសម្រេចលើពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពលើសំណើសុំ និងការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធ នៅក្នុងសំណុំរឿង ០០៤**

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី [redacted]:**

សូ មូស្សេរ្ឌី
Susana TOMANOVIĆ
Neville SORAB

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "ពាក្យសុំធ្វើមោឃភាពលើសំណើសុំ និងការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធ នៅក្នុងសំណុំរឿង ០០៤" ដែលបានដាក់ដោយសហមេធាវីការពារក្ដីរបស់ [redacted] ("សហមេធាវីការពារក្ដី" និង "ម្ចាស់ពាក្យសុំ") នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ("ពាក្យសុំ")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ និងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark HARMON បានបញ្ជូនលិខិតចំនួន៤ច្បាប់ទៅប្រធានអង្គភាពគាំពារជនរងគ្រោះ ដោយស្នើសុំព័ត៌មានបន្ថែមពី ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគេមិនបានផ្ដល់ "ព័ត៌មានលម្អិតគ្រប់គ្រាន់អំពីអំពើឧក្រិដ្ឋដែលបានចោទប្រកាន់" ("សំណើសុំព័ត៌មានបន្ថែម")[2]។

---

[1] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤"), ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពលើសំណើសុំ និងការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធ នៅក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ និងបានជូនដំណឹង នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧, ឯកសារ D370/1/1/2 ("ពាក្យសុំ")។ *សូមមើលផងដែរ* សំណុំរឿង ០០៤, សំណើបន្ទាន់សុំការអនុញ្ញាតដើម្បីដាក់ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពសំណើសុំ និងការប្រើប្រាស់ព័ត៌មានបន្ថែមទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធនានា ទៅក្នុងសំណុំរឿង ០០៤ តែមួយភាសា, ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧, ឯកសារ D370/1/1/1។

[2] សំណុំរឿង ០០៤, លិខិតពីចៅក្រម Mark HARMON ផ្ញើជូនប្រធានអង្គភាពគាំពារជនរងគ្រោះ [redacted]៖ សំណើសុំព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានមេធាវី, ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤, ឯកសារ D222 ("លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D222)")។ សំណុំរឿង ០០៤, លិខិតពីចៅក្រម Mark HARMON ផ្ញើជូនប្រធានអង្គភាពគាំពារជនរងគ្រោះ [redacted]៖ សំណើសុំព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានមេធាវី, ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤, ឯកសារ D223 ("លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D223)")។ សំណុំរឿង ០០៤, លិខិតពីចៅក្រម Mark HARMON ផ្ញើជូនប្រធានអង្គភាពគាំពារជនរងគ្រោះ [redacted]៖ សំណើលើក

2. នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ សហមេធាវីការពារក្ដីបានដាក់ពាក្យសុំស្នើឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើសំណើសុំព័ត៌មានបន្ថែម និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធនានា នៅក្នុងសំណុំរឿង[3] ដែលត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧[4]។

3. នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ដោយមានការណែនាំពីអង្គបុរេជំនុំជម្រះ[5] សហមេធាវីការពារក្ដីបានដាក់ពាក្យសុំធ្វើមោឃភាពលើសំណើសុំព័ត៌មានបន្ថែម និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធ។ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់គាត់[6] ហើយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ សហមេធាវីការពារក្ដីបានដាក់ការឆ្លើយតប[7]។

---

ទីពីរសុំព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤, ឯកសារ ("លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D234)")។ សំណុំរឿង ០០៤, លិខិតពីចៅក្រម Mark HARMON ផ្ញើជូនប្រធានអង្គភាពគាំពារជនរងគ្រោះ [redacted]៖ សំណើលើកទីបីសុំព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤, ឯកសារ ២០១៤, D235 ("លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D235)")។

[3] សំណុំរឿង ០០៤, ពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើសំណើសុំ និងការប្រាស់ប័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធនានា នៅក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧, ឯកសារ D370។

[4] សំណុំរឿង ០០៤, ដីកាសម្រេចលើពាក្យសុំរបស់ [redacted] ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពឯកសារមួយចំនួនពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧, ឯកសារ D370/1។

[5] *សូមមើល* សំណុំរឿង ០០៤, សារអេឡិចត្រូនិកពីអង្គបុរេជំនុំជម្រះផ្ញើជូនភាគីទាំងអស់នៅក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧។

[6] សំណុំរឿង ០០៤, ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពលើសម្ភារៈមួយចំនួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧, ឯកសារ D370/1/1/3 ("ចម្លើយតប")។

[7] សំណុំរឿង ០០៤, ការឆ្លើយតបរបស់ [redacted] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពលើសំណើសុំ និងការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធ នៅក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧, ឯកសារ D370/1/1/5 ("ការឆ្លើយតប")។

## II. ភាពអាចទទួលយកបាន

4. សហមេធាវីការពារក្តីអះអាងថា ពាក្យសុំនេះអាចទទួលយកបាន ពីព្រោះវាមានសំអាងហេតុគ្រប់គ្រាន់ និងទាក់ទងកំហុសនីតិវិធីដែលមិនបើកផ្លូវឧទ្ធរណ៍ ព្រមទាំងមាន "មូលដ្ឋានត្រឹមត្រូវ"[8]។ ពួកគេផ្តល់ទឡ្ហីករណ៍ថា ពួកគេបានបង្ហាញពីមូលដ្ឋានគតិយុត្តសម្រាប់ពាក្យសុំនេះ "ដោយបានជួបការលំបាក" ដើម្បីកំណត់អត្តសញ្ញាណសម្ភារៈដែលមានកំហុសនីតិវិធី និងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានសម្រេចថា ពាក្យសុំមិនមានមូលដ្ឋានច្បាស់លាស់នោះឡើយ[9]។

5. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា ពាក្យសុំ បានដាក់មិនទាន់ពេលវេលា ហើយអាស្រ័យហេតុនេះមិនអាចទទួលយកបានឡើយ ដោយធ្វើការគូសបញ្ជាក់ថា ពាក្យសុំនេះដែលត្រូវបញ្ជូនទៅអង្គបុរេជំនុំជម្រះ ត្រូវបានដាក់មួយសប្តាហ៍ បន្ទាប់ពីសេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ បើទោះបីសម្ភារៈដែលរងការជំទាស់អាចរកបានពីសំណាក់ម្ចាស់ពាក្យសុំ តាំងពីខែធ្នូ ឆ្នាំ២០១៥[10]។ គាត់ផ្តល់ទឡ្ហីករណ៍ថា យោងតាមវិធានផ្ទៃក្នុង ៧៦(២) ពាក្យសុំដើម្បីប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំធ្វើមោឃភាពសំណើត្រូវតែបានដាក់ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ហើយថា ការអនុញ្ញាតឲ្យដាក់ពាក្យសុំក្រោយពេលកំណត់នឹង "មិនស៊ីសង្វាក់គ្នាជាមួយនឹងលក្ខខណ្ឌតម្រូវសម្រាប់កិច្ចដំណើរការនីតិវិធីដ៏មានប្រសិទ្ធភាព[11]។

6. សហមេធាវីការពារក្តីឆ្លើយតបថា សហព្រះរាជអាជ្ញាអន្តរជាតិបញ្ចូលលក្ខណវិនិច្ឆ័យបន្ថែមមួយដោយមិនត្រឹមត្រូវទៅក្នុងការពិចារណាលើភាពអាចទទួលយកបាន[12]។ ដែនកំណត់ពេលវេលាក្នុងវិធានផ្ទៃក្នុង ៧៦(២) គ្រាន់តែកំណត់ថាតើពេលណាដែលភាគីអាចដាក់ពាក្យសុំប្តឹងទៅអង្គបុរេជំនុំជម្រះប៉ុណ្ណោះ[13]។ ដូច្នេះ ការកំណត់ពេលវេលាក្នុងការដាក់ពាក្យសុំធ្វើមោឃភាពនេះគួរតែមានទំនាក់ទំនង

---

[8] ពាក្យសុំ, កថាខណ្ឌ ២០-២២។

[9] ពាក្យសុំ, កថាខណ្ឌ ២២។

[10] ចម្លើយតប, កថាខណ្ឌ ២ *ដោយយោងលើ* សំណុំរឿង ០០៤, សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ [redacted], ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧, ឯកសារ D368។

[11] ចម្លើយតប, កថាខណ្ឌ ២។

[12] ការឆ្លើយតប, កថាខណ្ឌ ៥។

[13] ការឆ្លើយតប, កថាខណ្ឌ ៦។

ជាមួយសហចៅក្រមស៊ើបអង្កេតតែម្នាក់ឯងប៉ុណ្ណោះ[14]។ សហព្រះរាជអាជ្ញាអន្តរជាតិបានខកខានបន្ថែមទៀតក្នុងការជំទាស់ទៅនឹងសេចក្តីសម្រេចអនុញ្ញាតឱដាក់ពាក្យសុំប្តឹងទៅអង្គបុរេជំនុំជម្រះ[15]។

7. វិធានផ្ទៃក្នុង ៧៦(៤) ផ្តល់ឱ្យអង្គបុរេជំនុំជម្រះនូវយុត្តាធិការក្នុងការកំណត់ពីភាពអាចទទួលយកបាននៃពាក្យសុំធ្វើមោឃភាព ដែលខ្លួនអាចប្រកាសថា ពាក្យសុំមិនអាចទទួលយកបាន នៅពេលពាក្យសុំមានទំនាក់ទំនងនឹងដីកាដែលបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ ពុំមានមូលដ្ឋានច្បាស់លាស់ ឬមិនបង្ហាញសំអាងហេតុគ្រប់គ្រាន់[16]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ពាក្យសុំនេះមានសំអាងហេតុគ្រប់គ្រាន់ មិនពាក់ព័ន្ធនឹងដីកាដែលបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ និងមិនមែនពុំមានមូលដ្ឋានច្បាស់លាស់ដែលធ្វើឱ្យរារាំងស្ទះដល់លទ្ធភាពជោគជ័យឡើយ។

8. អង្គបុរេជំនុំជម្រះនាពេលថ្មីៗបានសម្រេចថា យោងតាមការអានរួមគ្នានៃវិធានផ្ទៃក្នុង ៦៦(១) វិធានផ្ទៃក្នុង ៦៧(១) និង វិធានផ្ទៃក្នុង ៧៦(២) និងយោងតាមវិធានផ្ទៃក្នុង ២១(១) ដែលថា "កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ" ត្រូវបានបិទបញ្ចប់ជាផ្លូវការ ដោយបានចេញដីកាដំណោះស្រាយ ហើយពុំមាននៅពេលនោះទេ ដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីអំពីបំណងរបស់ខ្លួនក្នុងការបិទបញ្ចប់កិច្ចស៊ើបសួរនេះ[17]។ ការរិតត្បិតលើការដាក់ពាក្យសុំធ្វើមោឃភាពរវាងការបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា និងការចេញដីកាដំណោះស្រាយអាចដកហូតពីជនត្រូវចោទនូវឧបាស្រ័យលើវិការៈនីតិវិធីដែលអាចកើតមាន នៅក្នុងអំឡុងពេលនេះ។ ដូច្នេះ អង្គបុរេជំនុំជម្រះចាត់ទុកថា ពាក្យសុំនេះបានដាក់ទាន់ពេលវេលា។

9. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចថា ពាក្យសុំអាចទទួលយកបាន។

---

[14] ការឆ្លើយតប, កថាខណ្ឌ ៦-៧។

[15] ការឆ្លើយតប, កថាខណ្ឌ ៨។

[16] សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៤), សេចក្តីសម្រេចលើពាក្យសុំរបស់ [redacted] សុំឱ្យធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨, ឯកសារ D257/1/8 ("សេចក្តីសម្រេចលើពាក្យសុំធ្វើមោឃភាពភស្តុតាងបានមកពីទារុណកម្ម"), កថាខណ្ឌ ១០។

[17] សេចក្តីសម្រេចលើពាក្យសុំធ្វើមោឃភាពភស្តុតាងបានមកពីទារុណកម្ម, កថាខណ្ឌ ១១-១២។



PRE-TRIAL CHAMBER E.C.C.C.

## III. អង្គសេចក្ដី

### ក. សារណា

10. សហមេធាវីការពារក្ដីស្នើសុំអង្គបុរេជំនុំជម្រះធ្វើមោឃភាព អនុលោមតាមវិធានផ្ទៃក្នុង ២១ វិធានផ្ទៃក្នុង ៤៨ និងវិធានផ្ទៃក្នុង ៧៦ លើសំណើសុំព័ត៌មានបន្ថែម និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធនានាដែលប្រមូលបានពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[18]។ ពួកគេអះអាងថា ការចាត់តាំងសំណួរដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទៅអង្គភាពជនជនរងគ្រោះគឺត្រូវបានធ្វើឡើង *ហួសសិទ្ធិអំណាច* និងក្នុងការរំលោភលើវិធានផ្ទៃក្នុង ២៣(៤) ២៣*ស្ទួន*(២) ៥៩ និង ៦២ នៅពេលរក្សាទុក សម្ភារៈស៊ើបអង្កេតដែលប្រមូលបានតាមរយៈសំណើសុំព័ត៌មានបន្ថែមដែលមានកំហុសនិតិវិធី និងមិនអាចជឿជាក់បាន[19]។ ពួកគេបញ្ជាក់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពុំអាចត្រូវបានសួរសំណួរជាសាក្សីធម្មតាឡើយ អនុលោមតាមវិធានផ្ទៃក្នុង ២៣*ស្ទួន*(២) និង២៣(៤) និងថា សហចៅក្រមស៊ើបអង្កេតមិនអាចអនុវត្តឆន្ទានុសិទ្ធិការអនុវត្តការស្ដាប់ចម្លើយបែបនេះឡើយ[20]។ ការសួរសំណួរទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប៉ះពាល់សុចរិតភាពនៃកិច្ចស៊ើបសួរ និងបង្កព្យសនកម្មដល់សិទ្ធិរបស់ម្ចាស់ពាក្យសុំ និងភាគីផ្សេងៗទៀត[21]។

11. សហមេធាវីការពារក្ដីផ្ដល់ទឡ្ហីករណ៍ថា សំណើសុំព័ត៌មានបន្ថែមគឺជា "កិច្ចស៊ើបសួរ អនុលោមតាមវិធានផ្ទៃក្នុង ៤៨ ពីព្រោះថា សំណើសុំទាំងនេះពាក់ព័ន្ធនឹងការផ្ដល់ "សម្ភារៈជាភស្ដុតាង" ដែលជាចុងក្រោយត្រូវបានដាក់នៅក្នុងសំណុំរឿង[22]។ ដូច្នេះ សំណើសុំព័ត៌មានបន្ថែមនេះនាំឲ្យការផ្ទេរកិច្ច

---

[18] *សូមមើល* សំណើសុំ, ទំព័រ ១។ *សូមមើលផងដែរ* សំណុំរឿង ០០៤, ពាក្យសុំរបស់ [redacted] សុំមោឃភាពសំណើ និងការប្រើប្រាស់ព័ត៌មានបន្ថែម និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ – ឧបសម្ព័ន្ធ ក, ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧, ឯកសារ D370/1/1/2.2។ សំណុំរឿង ០០៤, ពាក្យសុំរបស់ [redacted] សុំមោឃភាពសំណើ និងការប្រើប្រាស់ព័ត៌មានបន្ថែម និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ – ឧបសម្ព័ន្ធ ខ, ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧, ឯកសារ D370/1/1/2.3។

[19] ពាក្យសុំ, កថាខណ្ឌ ២៣-២៤។

[20] ពាក្យសុំ, កថាខណ្ឌ ២៣។

[21] ពាក្យសុំ, កថាខណ្ឌ ២៤។

[22] ពាក្យសុំ, កថាខណ្ឌ ២៥-២៦។

សួរ *ហួសសិទ្ធិអំណាច* ដល់អង្គភាពគាំពារជនរងគ្រោះ ដែល "ដើរតួនាទីរដ្ឋបាលសុទ្ធសាធ"[23]។ ពួកគេអះអាងថាឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការពុំមែនជាឆន្ទានុសិទ្ធិដាច់ខាតឡើយ[24] ហើយថា ពួកគេអាចចាត់តាំងមុខងារស៊ើបសួរទៅឱ្យ អ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក ឬនគរបាលយុត្តិធម៌ប៉ុណ្ណោះ បន្ទាប់ពីការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស និងការបំពេញលក្ខខណ្ឌមួយចំនួន អនុលោមតាមវិធានផ្ទៃក្នុង ៥៥(៩) និង ៦២[25]។ វិធានផ្ទៃក្នុង ៥៥(៥) ត្រូវបានជំនួសបន្ថែមដោ *ច្បាប់ជាក់លាក់* នៃវិធានផ្ទៃក្នុង ៥៩(៦)[26] ដែលចែងថាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវធ្វើឡើងតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួសអាចត្រូវបានចាត់តាំងទៅឱ្យតែអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក ប៉ុណ្ណោះ[27]។

12. សហមេធាវីការពារក្តីក៏បានអះអាងថែមទៀតថា ទម្រង់នៃការសួរសំណួរដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺមានភាពមិនសមស្រប និងធ្វើឱ្យប្រឡាក់ប្រឡូសកិច្ចស៊ើបសួរ[28]។ ពួកគេបញ្ជាក់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមាន "ផលប្រយោជន៍ជាក់លាក់" ក្នុងការបង្ហាញអំពើឧក្រិដ្ឋភាព និងការភ្ជាប់ចំណុចនេះទៅនឹងចារីដែលត្រូវបានចោទ ហើយពាក្យសុំរបស់ពួកគេត្រូវបានផ្តល់ឱ្យថា "មានតម្លៃជាភស្តុតាងតិចតួច នៅ អ.វ.ត.ក[29]។ ពួកគេបញ្ជាក់ពីក្តីបារម្ភរបស់ខ្លួនលើបញ្ជីសំណួរបញ្ជាក់ដែលបានផ្តល់ជូនក្នុងទម្រង់ជាឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងសំណើសុំព័ត៌មានបន្ថែម[30] និងអង្គហេតុដែលថា ដំណើរការនៃការសួរសំណួរមិនត្រូវបានកត់ត្រាស្របតាមវិធានផ្ទៃក្នុង ២៥[31]។ ពួកគេសន្និដ្ឋានថា ការដាក់បញ្ចូលនូវព័ត៌មានបន្ថែមទៅក្នុងសំណុំរឿងគឺរំលោភបំពានទៅលើសិទ្ធិរបស់ម្ចាស់ពាក្យសុំក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌

[23] ពាក្យសុំ, កថាខណ្ឌ ២៩។

[24] ពាក្យសុំ, កថាខណ្ឌ ២៧។

[25] ពាក្យសុំ, កថាខណ្ឌ ២៨-៣០។

[26] ពាក្យសុំ, កថាខណ្ឌ ៣១។

[27] ពាក្យសុំ, កថាខណ្ឌ ៣០។

[28] ពាក្យសុំ, កថាខណ្ឌ ៣៦-៤៤។

[29] ពាក្យសុំ, កថាខណ្ឌ ៣៧-៣៨។

[30] ពាក្យសុំ, កថាខណ្ឌ ៤០។

[31] ពាក្យសុំ, កថាខណ្ឌ ៤៣។

និងការធានាឱ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស[32]។

13. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សំណើសុំព័ត៌មានបន្ថែម និងការដាក់ព័ត៌មានបន្ថែមគឺធ្វើឡើងស្របតាមវិធានផ្ទៃក្នុង[33]។ ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានចេតនាចាត់ទុកការស្តាប់ចម្លើយផ្លូវការថាជាព័ត៌មានបន្ថែម ដែលទទួលបានតាមរយៈអង្គភាពគាំពារជនរងគ្រោះដែលគ្រាន់តែជាផ្តល់ជំនួយ ស្របតាមវិធានផ្ទៃក្នុង ១២*ស្ទួន*(១)(ខ)[34]។ វិធីនេះគឺនាំទៅរកកិច្ចស៊ើបសួរដ៏មានប្រសិទ្ធភាព និងត្រឹមត្រូវល្អនៅក្នុងឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[35]។

14. សហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់បន្ថែមទៀតថា ទាំងអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាំងអង្គភាពគាំពារជនរងគ្រោះបានបំពេញការងារដោយមិនលម្អៀង ហើយថា សំណួរដែលបានស្នើឡើងគឺស្របតាមបញ្ញត្តិទេសស៊ើបអង្កេតត្រឹមត្រូវ[36]។ ការអះអាងអំពីភាពលម្អៀងជាទូទៅមានលក្ខណៈលឿនពេក និងជាការស្មានៗតែប៉ុណ្ណោះ ពីព្រោះវត្តមាននៃព័ត៌មានបន្ថែមនៅក្នុងសំណុំរឿងមិនបញ្ជាក់ថា ព័ត៌មានទាំងនោះទទួលបានការផ្តល់ទម្ងន់ភស្តុតាងហួសហេតុ[37]។ វិធីរបស់សហមេធាវីការពារក្តីនេះនឹង "មានសារៈសំខាន់ដល់ការច្រានចោលភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនានា"[38]។

15. សហមេធាវីការពារក្តីឆ្លើយតបថា សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានបង្ហាញថា អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំពេញកិច្ច ក្នុងអំណាចស្របច្បាប់របស់ខ្លួនក្នុងការធ្វើប្រតិភូកម្មបំពេញកិច្ចស៊ើបសួរទៅឱ្យអង្គភាពគាំពារជនរងគ្រោះ[39]។ ពួកគេបញ្ជាក់ម្តងហើយម្តងទៀតថា

---

[32] ពាក្យសុំ, កថាខណ្ឌ ៤៥។

[33] ចម្លើយតប, កថាខណ្ឌ ៣-៦។

[34] ចម្លើយតប, កថាខណ្ឌ ៣-៤។

[35] ចម្លើយតប, កថាខណ្ឌ ៦។

[36] ចម្លើយតប, កថាខណ្ឌ ៧-១០។

[37] ចម្លើយតប, កថាខណ្ឌ ១១-១៣។

[38] ចម្លើយតប, កថាខណ្ឌ ១៥។

[39] ការឆ្លើយតប, កថាខណ្ឌ ១១។

ការសួរសំណួរទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគឺត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃ *ច្បាប់ពិសេស* យ៉ាងតឹងរ៉ឹងនៃវិធានផ្ទៃក្នុង ២៣(៤) និង ៥៩[40]។ សហចៅក្រមស៊ើបអង្កេតពុំមានមធ្យោបាយក្នុងការធានាថា ការសួរដេញដោលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹង រដ្ឋប្បវេណីត្រូវបានធ្វើឡើងដោយមិនលម្អៀង ហើយវាអាចត្រឹមស្មានថា ការសួរដេញដោលត្រូវបានធ្វើឡើងដោយគោរពតាមក្រមសីលធម៌[41]។ សហមេធាវីការពារក្ដីអះអាងជាចុងក្រោយថា សហព្រះ រាជអាជ្ញាអន្តរជាតិកំណត់មិនត្រឹមត្រូវចំពោះទឡ្ហីករណ៍របស់ខ្លួនទាក់ទងនឹងការធ្វើឱ្យខូចខាតការស៊ើបអង្កេត និងព្យសនកម្មដែលបណ្ដាលមកពីវត្តមាននៃ "សម្ភារៈមិនត្រឹមត្រូវ" នៅក្នុងសំណុំរឿង[42]។ ភាពមិនអាចទុកចិត្តបានយ៉ាងខ្លាំងលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងកំហុសនីតិវិធីដែលរងការចោទប្រកាន់ក្នុងការទទួលបានព័ត៌មានបន្ថែមនាំដល់ការធ្វើមោឃភាពដែលជាការជួសជុលដ៏សមស្រប និងតែមួយគត់ដល់កំហុសនីតិវិធី[43]។

## ខ. កិច្ចពិភាក្សា

16. វិធានផ្ទៃក្នុង ៧៣(ខ) បង្ហាញពីយុត្តាធិការផ្ដាច់មុខរបស់អង្គបុរេជំនុំជម្រះលើពាក្យសុំធ្វើមោឃភាព។ អនុលោមតាមវិធានផ្ទៃក្នុង ៤៨ ការពិចារណាលើពាក្យសុំធ្វើមោឃភាពចាំបាច់ត្រូវកំណត់៖ ១) ថាតើមានភាពមិនប្រក្រតីនីតិវិធីដែរ ឬទេ និង ២) ក្នុងករណីដែលកំហុសត្រូវបានរកឃើញថាកើតមាន ត្រូវកំណត់ថាតើម្ចាស់ពាក្យសុំទទួលរងព្យសនកម្មដែរ ឬទេ[44]។

17. ចាប់ពីចំណុចចាប់ផ្ដើម អង្គបុរេជំនុំជម្រះរម្លឹកថា ការប្រមូលភស្តុតាងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរត្រូវបានកំណត់ដោយគោលការណ៍សេរីភាពនៃភស្តុតាង ដែលយោងតាមគោលការណ៍នេះ ភស្តុតាងទាំងអស់គឺអាចទទួលយកបាន ហើយជាទូទៅមានតម្លៃជាភស្តុតាងស្មើគ្នា[45]។ មាត្រា ២៣ថ្មី នៃ

---

[40] ការឆ្លើយតប, កថាខណ្ឌ ១៣។

[41] ការឆ្លើយតប, កថាខណ្ឌ ១៧-១៨។

[42] ការឆ្លើយតប, កថាខណ្ឌ ១៦-២៣។

[43] ការឆ្លើយតប, កថាខណ្ឌ ២៤។

[44] *សូមមើលឧទាហរណ៍*, សេចក្ដីសម្រេចលើពាក្យសុំធ្វើមោឃភាពភស្តុតាងបានមកពីទារុណកម្ម, កថាខណ្ឌ ១៤។

[45] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤/១") (អបជ៥០), សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨,

ច្បាប់ បង្កើត អ.វ.ត.ក ឆ្លុះបញ្ចាំងពីគោលការណ៍នេះដោយកំណត់ថា "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតដោយផ្អែកលើមូលដ្ឋាននៃព័ត៌មាន *ដែលទទួលបានពីស្ថាប័ននានា*" [46]។ ក្នុងករណីនេះ វិធានផ្ទៃក្នុង ៥៥(៥) អនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យសហចៅក្រមស៊ើបអង្កេត "ចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត" និង "ស្វែងរកព័ត៌មាន និងជំនួយពីបរទេស អង្គការសហប្រជាជាតិ ឬអង្គការអន្តររដ្ឋាភិបាល ឬអង្គកាក្រៅរដ្ឋាភិបាល *ឬ ប្រភពសមស្របដទៃទៀត*"[47]។

18. ដូច្នេះ ពុំមានបទប្បញ្ញត្តិនៅក្នុងច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ដែលហាមសហចៅក្រមស៊ើបអង្កេតពីការស្នើសុំជំនួយ ឬការប្រមូលព័ត៌មានពីស្ថាប័នដទៃទៀត រួមទាំងអង្គភាពគាំពារជនរងគ្រោះផង ដែលមានភារកិច្ចជាពិសេសក្នុងការគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រោមការត្រួតពិនិត្យរបស់ចៅក្រម[48]។

19. ងាកទៅពិនិត្យលក្ខណៈនៃជំនួយដែលបានស្នើសុំពីអង្គភាពគាំពារជនរងគ្រោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការសួរដេញដោលម្ចាស់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើងដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអាចចាត់ទុកថាជាការចាត់តាំងអំណាចឱ្យធ្វើការស្តាប់ចម្លើយជាផ្លូវការដែលជាលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី ស្របតាមវិធានផ្ទៃក្នុង ២៣(៤) និង ៥៩។ ចំណុចនេះបង្ហាញយ៉ាងច្បាស់ថា អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានចាត់ទុក ឬមានចេតនាចាត់ទុកការសួរដេញដោលម្ចាស់ពាក្យសុំពីសំណាក់អង្គភាពគាំពារជនរងគ្រោះថាជាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីជាផ្លូវការឡើយ។ បើទោះបីជាគាត់បង្ហាញ "បញ្ជីសំណួរបញ្ជាក់"

---

ឯកសារ D308/3/1/20 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១"), កថាខណ្ឌ ៤៤ *ដោយយោងលើ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៣២១។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង, មាត្រា ៤២៧។ J. PRADEL, Procédure pénale, Cujas, ១៤th ed., ២០០៨-២០០៩, ទំព័រ ៣៦៤។ F. DEBOVE, F. FALLETTI and E. DUPIC, *Précis de droit pénal et de procédure pénale*, Presses Universitaires de France, 5th ed., ២០១៣, ទំព័រ ៦៩៧។

[46] ច្បាប់បង្កើត អ.វ.ត.ក, មាត្រា ២៣ថ្មី (ការបញ្ជាក់បន្ថែម)។ *សូមមើលផង ដែរ*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១, កថាខណ្ឌ ៤៤។

[47] វិធានផ្ទៃក្នុង ៥៥(៥)(គ) (ការបញ្ជាក់បន្ថែម)។

[48] វិធានផ្ទៃក្នុង ១២*ស្ទួន* (១)(ខ)។

ដែលត្រូវសួរដោយអង្គភាពគាំពារជនរងគ្រោះក៏ដោយ[49] ក៏ព័ត៌មានដែលត្រូវបានធ្វើឡើងក្រោមការត្រួតពិនិត្យរបស់គាត់ មានចេតនាយ៉ាងច្បាស់លាស់ក្នុងជួយដល់ការវាយតម្លៃលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងប្រើក្នុងដំណើរការសម្រិតសម្រាំងដំបូង ដើម្បីកំណត់ថាតើម្ចាស់ពាក្យសុំគួរត្រូវបានស្តាប់ចម្លើយជាផ្លូវការដែរ ឬទេ[50]។ អង្គហេតុដែលថា គាត់បានស្នើអង្គភាពគាំពារជនរងគ្រោះបញ្ជូនអនុស្សារណៈអន្តរការិយាល័យដោយសង្ខេបពីព័ត៌មានបន្ថែម[51] មិនមែនប្រតិចារឹកអំពីការសួរដេញដោលក៏បង្ហាញថា គាត់ពុំមានចេតនាចង់ឲ្យសម្ភារៈដែលទទួលបានមានទម្ងន់ដូចគ្នានឹងការស្តាប់ចម្លើយផ្លូវការនៃដើមបណ្តឹងរដ្ឋប្បវេណីដែរ។

20. អង្គបុរេជំនុំជម្រះគត់សម្គាល់ឃើញបន្ថែមទៀតថា អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានណែនាំយ៉ាងច្បាស់លាស់ទៅអង្គភាពគាំពារជនរងគ្រោះឲ្យទាក់ទងជាមួយនឹងម្ចាស់ពាក្យសុំដើម្បី "បំពេញពាក្យសុំរបស់ពួកគេ" និង "ព័ត៌មានដែលខ្វះខាត"[52]។ ដូច្នេះ ព័ត៌មានបន្ថែមពីសកម្មភាពនេះត្រូវបានដាក់ភ្ជាប់មកជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធ និងមិនធ្លាប់ចាត់ទុកជាការស្តាប់ចម្លើយផ្លូវការនោះទេ។

21. សំអាងលើហេតុផលដែលបានបញ្ជាក់ខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គភាពគាំពារជនរងគ្រោះមិនបានអនុវត្តកិច្ចស៊ើបសួរដែលត្រូវបានចាត់តាំងណាមួយ ដើម្បីជំនួសសហចៅក្រម ស៊ើបអង្កេត អនុលោមតាមខ្លឹមសារនៃវិធានផ្ទៃក្នុង ៥៥(៩) ៥៩(៦) និង ៦២ ទេ ប៉ុន្តែផ្ទុយទៅវិញបានជួយជនរងគ្រោះយ៉ាងត្រឹមត្រូវ ដើម្បីបំពេញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្រោមការត្រួតពិនិត្យរបស់អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមវិធានផ្ទៃក្នុង ១២*ស្ទួន*(១)(ខ)។

22. អាស្រ័យហេតុនេះ គ្មានកំហុសនីតិវិធីត្រូវបានបញ្ជាក់ដែលអាចផ្តល់យុត្តិកម្មដល់មោឃភាពលើសំណើសុំព័ត៌មានបន្ថែម និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធនានានោះទេ។ កង្វល់ណាមួយដែលទាក់ទងនឹងភាពអាចជឿជាក់បាននៃព័ត៌មានបន្ថែមអាចនឹងមិនប៉ះពាល់សុពលភាពនៃពាក្យសុំតាំងខ្លួនជាដើម

[49] លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D222), នៅ ERN (KH) 01030148-01030153។

[50] លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D222), នៅ ERN (KH) 01030143-44។

[51] លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D222), នៅ ERN (KH) 01030154។

[52] លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D222), នៅ ERN (KH) 01030143-44។ លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D223), នៅ ERN (KH) 01030177-78។ លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D234), at ERN (KH) 01054845។ លិខិតផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ (D235), នៅ ERN (KH) 01054759។

បណ្ដឹងរដ្ឋប្បវេណីទេ ប៉ុន្តែគ្រាន់ប៉ះពាល់តម្លៃជាភស្តុតាងនៃព័ត៌មានទាំងនោះ ដែលត្រូវការវាយតម្លៃពេញលេញនៅដំណាក់កាលក្រោយទៀត។

## IV. សេចក្ដីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ យោងតាមសំឡេងជាឯកច្ឆ័ន្ទ៖**

- **យល់ឃើញថា** ពាក្យសុំនេះអាចទទួលយកបានតាមទម្រង់ច្បាប់។

- **បដិសេធ** ពាក្យសុំនេះ។

យោងតាមវិធានផ្ទៃក្នុង ៧៧(១៣) សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន Oliver BEAUVALLET ន័យ ធុល Kang Jin BAIK ហួត វុទ្ធី